# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចេញពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនវិចិត្រមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ កៅ-ស៊ឹម អ្នកត្រួតត្រាសិស្សនៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង


| | | |
|---|---|---|
| *ផ្នែកអក្សរសាស្ត្រ* | | *ទំព័រ* |
| ឃុនវិចិត្រមន្ត្រី ញ៉ុក-ថែម . . . | រឿងកុលាបប៉ៃលិន . . . . . . . . . . . . | ១៨១ |
| " " . . . . . | ពង្សាវតារប្រទេសចិន ស្រង់ចេញអំពីគោលចារិកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) . . | ១៩៤ |
| លោកអាចារ្យ គឹម-អាន . . . . . | រឿងព្រះបាទអសោកមហារាជ (តមក) . . . . | ២០៣ |
| អ្នកឧកញ៉ាបេស្ជាវិជ័យកែវ-ហង្ស | រឿងប្រលោមចិត្ត (ពាក្យកាព្យ) (តមក) . . . . | ២១៦ |
| ចម្លងចេញអំពីច្បាប់សាស្ត្រាស្លឹករឹត | រឿងព្រេងខ្មែរ: រឿងចៅធុងចៅសាញ់ . . . . | ២២៣ |
| *ផ្នែកសាសនា* | | |
| ដំណឹងអំពីក្រសួងធម្មការ . . . | អំពីការតាំងចៅអធិការថ្មី នៅវត្តនាគ (ក្នុងខែហ្វេវ្រីយេរ) . . . . . . . . . . . . . . . | ២៣៦ |
| " " . . . . . . . | ពិធីបុណ្យបញ្ចុះសីមានៅវត្តនាគ . . . . . . . | ២៣៩ |
| ឃុនវិចិត្រមន្ត្រី ញ៉ុក-ថែម . . . | ប្រស្នាធម៌អំពីព្រះនិព្វាន . . . . . . . . . . . | ២៤១ |


ឆ្នាំទី ១៥ — លេខ ៤ ប្រចាំខែអាព្រិល ១៩៤៣ ។

តំលៃផ្សារ: ១ ឆ្នាំ ១០ រៀល — ៦ ខែ: ៥ រៀល ។

# ប្រស្នាធម៌

## អំពីព្រះនិព្វាន។

បុច្ឆា: គេថាព្រះអរហន្តស្លាប់ទៅសូន្យមែនឬ?

វិសជ្ជនា: តាមធម្មតា យើងកេល់គ្នាដែលនៅជាបុថុជ្ជន មិនអាចយល់ច្បាស់ចាក់ធ្លុះគន្លឹះប្រស្នានេះបានទេ ប៉ុន្តែបើគិតទៅតាមស្នាមសំអានយោបល់ព្រះអរហន្តហាក់ដូចជាព្រះអរហន្តដល់មរណភាពទៅមិនមែនជាសូន្យឈឹងទេ ទើបលោកពោលថា ព្រះអរហន្តចូលនិព្វាន ឯព្រះនិព្វាននោះ ជាស្ថានរំលត់ទុក្ខ ប្រកបដោយសេចក្ដីសុខតែម្យ៉ាង ដូចព្រះពុទ្ធភាសិតថា "និព្វានំ បរមំ សុខំ" ព្រះនិព្វានជាធម្មជាតប្រកបដោយសេចក្ដីសុខយ៉ាងក្រៃលែង ។ មួយវិញទៀត ព្រះអរហន្តតែងយល់ថា ខន្ធ៥ជាតួទុក្ខ ជាទីប្រជុំកើតឡើងនៃទុក្ខ មានជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ និងមរណទុក្ខជាដើម ទើបលោកដកចិត្តចេញចាកខន្ធ៥ ឥតឧបាទាន ពិចារណាខន្ធទាំង៥ ឲ្យឃើញពិតតាមព្រះត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ខន្ធ៥កើតឡើងហើយតែងរលត់ទៅវិញជាធម្មតា ដូចមានសេចក្ដីសាកច្ឆារបស់ព្រះមហាសារីបុត្តត្ថេរនឹងយមកភិក្ខុ សំដែងទុកក្នុងសុត្តន្តបិដក ភាគទី ៣៣ គន្ថ៍ខន្ធសំយុត្ត មជ្ឈិមបណ្ណាសក: ថេរវគ្គទី ៤ បត្រ: ទី ១៩៨ មានសេចក្ដីសង្ខេបថា:

ក្នុងសម័យមួយនោះ មានភិក្ខុមួយរូបឈ្មោះយមកៈ កើតមានទិដ្ឋិអាក្រក់ យល់ខុសថា "អញដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដូចជាព្រះខីណាស្រពតែទំលាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់ខាតសូន្យវិនាសបាត់ទៅមិនកើតទៀតទេ" ។ ឯភិក្ខុទាំងឡាយជាច្រើនបានដឹងបានឮពាក្យនេះហើយ ក៏ចូលទៅរកយមកភិក្ខុហើយសួរថា លោកយល់ថាព្រះខីណាស្រពតែទំលាយខន្ធហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅរមែងដាច់ខាតសូន្យទៅមិនកើតទៀត មែនដូច្នេះទេ ? យមកភិក្ខុក៏ទទួលថា ខ្ញុំករុណាយល់ហើយ ពោលដូច្នេះមែន ។ ពួកភិក្ខុទាំងនោះក៏យល់ទាស់ថា ម្នាលអាវុសោយមកៈ លោកកុំពោលយ៉ាងនេះឡើយ លោកកុំពោលបង្កាច់ព្រះដ៏មានព្រះភាគ ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រោះព្រះអង្គមិនបានត្រាស់ថា ភិក្ខុជាខីណាស្រពតែទំលាយកាយហើយខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់ខាតសូន្យ មិនកើតទៀតយ៉ាងនេះទេ ។ ឯយមកភិក្ខុក៏មិនយល់ព្រមតាមភិក្ខុទាំងនោះឡើយ នៅតែប្រកាន់តាមយោបល់យល់ឃើញរបស់ខ្លួនដដែល ពួកភិក្ខុទាំងនោះក៏មិនអាចដោះស្រាយដូចម្តេចទៅទៀតបាន ទើបនាំគ្នាទៅនិមន្តព្រះសារីបុត្តត្ថេរ ឲ្យលោកជួយនិយាយពន្យល់ ដោះស្រាយសេចក្តីយល់ខុសរបស់យមកភិក្ខុផង ។ ទើបព្រះ

សារីបុត្តត្រឡប់ទៅសួរព្រះយមកភិក្ខុថា ម្នាលអាវុសោយមកៈ លោកមានសេចក្ដីយល់ឃើញ មានសភាពដូច្នេះពិតមែនឬ ? ។

យមកៈ ម្នាលអាវុសោ យ៉ាងហ្នឹងមែនហើយ ។

សារីបុត្ត ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះដូចម្ដេច រូបទៀងឬមិនទៀងទេ ។

យ. មិនទៀងទេ អាវុសោ ។

សា. ចុះវេទនា សញ្ញា សង្ខារ វិញ្ញាណ តើទៀងឬមិនទៀងទេ ។

យ. មិនទៀងទេ អាវុសោ ។

សា. ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះដូចម្ដេច លោកពិចារណាឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាសត្វឬ ។

យ. មិនមែនដូច្នោះទេ អាវុសោ ។

សា. ចុះលោកសំគាល់ពិចារណាឃើញថា សត្វមានក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឬ ។

យ. មិនមែនដូច្នោះទេ អាវុសោ ។

សា. ចុះលោកពិចារណាឃើញថា សត្វផ្សេងអំពីរូប វេទនា សញ្ញា សង្ខារ វិញ្ញាណទៅឬ ។

យ. មិនមែនដូច្នេះទេ ។

សា.  ចុះលោកពិចារណាឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណថាជាសត្វឬ ។

យ.  មិនមែនដូច្នោះទេ ។

សា.  ចុះលោកពិចារណាឃើញសត្វនេះថា មិនមានរូប មិនមានវេទនា មិនមានសញ្ញា មិនមានសង្ខារ មិនមានវិញ្ញាណឬ ។

យ.  មិនមែនដូច្នោះទេ ។

សា. ម្នាលអាវុសោយមកៈ កាលបើលោកកំណត់សត្វថាទៀងថាពិត ក្នុងបច្ចុប្បន្ននេះហើយ ទើបគួរលោកពោលថា អញដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដូចជាព្រះខីណាស្រព តែងរំលាយកាយហើយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងដាច់ខាតសូន្យទៅ មិនកើតទៀតទេដូច្នេះបាន ។

យ.  ម្នាលអាវុសោសារីបុត្ត កាលពីដើមខ្ញុំមិនដឹងថា ទិដ្ឋិរបស់ខ្ញុំនោះជាទិដ្ឋិខុសអាក្រក់ទេ ឥឡូវនេះខ្ញុំលះបង់ទិដ្ឋិអាក្រក់នោះហើយ ព្រោះបានស្ដាប់ព្រះធម្មទេសនារបស់ព្រះសារីបុត្តដ៏មានអាយុនេះ មួយវិញទៀត ខ្ញុំក៏បានសម្រេចធម៌វិសេសផងហើយ ។

សា.  ម្នាលអាវុសោយមកៈ បើជនទាំងឡាយគេសួរលោកហើងនេះថា ម្នាលអាវុសោភិក្ខុឯណា ជាព្រះអរហន្តខីណាស្រព ភិក្ខុ

នោះទំលាយកាយហើយ ។ អានមុខអំពីសេចក្តីស្លាប់ទៅទីងកើតទៀតឬ ដូច្នេះ តើលោកគប្បីព្យាករដូចម្តេចទៅ ។

យ. ម្នាលអាវុសោ បើមានគេសួរខ្ញុំយ៉ាងនេះ ខ្ញុំគប្បីព្យាករថា ម្នាលអាវុសោ រូបមិនទៀងទេ រូបឯណាមិនទៀង រូបនោះជាទុក្ខ រូបឯណាជាទុក្ខ រូបនោះរលត់ទៅ ដល់នូវសេចក្តីវិនាសទៅ ឯវេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលមិនទៀងជាទុក្ខក៏រលត់ទៅ ដល់នូវសេចក្តីវិនាសទៅដែរ ។

សា. ម្នាលអាវុសោយមកៈ ត្រូវហើយៗ ខ្ញុំនឹងធ្វើសេចក្តីឧបមាឲ្យលោកស្តាប់ ដើម្បីឲ្យសេចក្តីនោះច្បាស់លាស់ឡើងទៀត ។

ម្នាលអាវុសោយមកៈ ដូចជាគហបតីឬបុត្ររបស់គហបតីជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ប្រកបដោយការរក្សាខ្លួនយ៉ាងមាំមួន តោះបើបុរសណាមួយមានប្រាថ្នាចង់សម្លាប់គហបតីឬគហបតីបុត្រនោះ ក៏គិតត្រិះរិះយ៉ាងនេះថា គហបតីឬគហបតីបុត្រនេះ ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានការរក្សាខ្លួនមាំមួន អញមិនងាយនឹងទៅសម្លាប់គេបានទេ ដូច្នេះ មានតែអញចូលទៅនៅបំរើ ធ្វើបាយល្បួងលួងលោមឲ្យបានស្និទ្ធទុកចិត្តគ្នាសិនសឹមសម្លាប់ បុរសនោះចូលទៅសូមនៅបំរើគហបតីឬគហបតី-បុត្រនោះ ប្រព្រឹត្តជាទីគាប់ចិត្ត ពោលតែពាក្យជាទីស្រឡាញ់ពេញចិត្ត ឯគហបតីឬគហបតីបុត្រ ក៏ជឿទុកចិត្តថា បុរសនោះជាមិត្តល្អផង

ជាអ្នកមានចិត្តល្អផង ក៏មានសេចក្តីស្និទ្ធស្នាលនឹងបុរសនោះ លុះវេលាក្រោយមកគហបតីឬគហបតីបុត្រ ក៏ពុំនៅក្នុងទីស្នាក់ បុរសនោះក៏សម្លាប់គហបតីឬគហបតីបុត្រនោះ ដោយសស្ត្រាដ៏មុត ។

ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនេះដូចម្តេច កាលដែលបុរសចូលទៅសូមនៅបម្រើគហបតីឬគហបតីបុត្រក្តី វេលាធ្វើការជាទីពេញចិត្តក្តី វេលានៅក្នុងទីស្នាក់ក្តី ក៏គហបតីឬគហបតីបុត្រនោះមិនដឹងថាបុរសនេះជាអ្នកសម្លាប់ខ្លួនដូច្នេះមែនទេ ។

យ. ត្រូវហើយអាវុសោ ។

សា. ម្នាលអាវុសោ បុថុជ្ជនអ្នកមិនចេះដឹង មិនធ្លាប់ឃើញពួកព្រះអរិយ មិនឈ្លាសវៃក្នុងអរិយធម៌ មិនធ្លាប់ឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរសធម៌ រមែងមើលឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួនខ្លះ ឃើញខ្លួនថាមានរូប វេទនា សញ្ញា សង្ខារ វិញ្ញាណខ្លះឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណក្នុងខ្លួនខ្លះ ឃើញខ្លួនក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណខ្លះ ។ បុថុជ្ជននោះរមែងមិនដឹងច្បាស់តាមសេចក្តីពិតថា រូប វេទនា សញ្ញា សង្ខារ-វិញ្ញាណ មិនទៀងជាទុក្ខមិនមែនជាខ្លួនមានបច្ច័យតាក់តែងឡើង រមែងមិនដឹងច្បាស់នូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអ្នកសម្លាប់ឡើយ ។ បុថុជ្ជននោះរមែងចូលទៅប្រកាន់ខ្ជាប់ នូវរូប វេទនា សញ្ញា

សង្ខារ វិញ្ញាណ ថាជារបស់អញ ។ ឧបាទានក្ខន្ធទាំង៥នេះ ដែលបុថុជ្ជន ចូលទៅប្រកាន់ខ្ជាប់ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីជាទុក្ខ អស់កាលជាអង្វែង ។

ម្នាលអាវុសោយមកៈ ឯព្រះអរិយសាវកជាអ្នកចេះដឹង ធ្លាប់បានឃើញពួកព្រះអរិយៈ ឈ្លាសវៃក្នុងអរិយធម៌ ធ្លាប់បានឃើញពួកសប្បុរស ឈ្លាសវៃក្នុងសប្បុរិសធម៌ រមែងមិនឃើញ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន មិនឃើញខ្លួនថា មានរូប វេទនា សញ្ញា សង្ខារ វិញ្ញាណក្នុងខ្លួនក្តី មិនឃើញខ្លួនក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណក្តី ។ អរិយសាវកនោះ រមែងដឹងច្បាស់តាមពិតថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនទៀងជាទុក្ខមានបច្ច័យតាក់តែងឡើង ។ ដឹងច្បាស់តាមពិតថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ហ្នឹងឯងជាអ្នកសម្លាប់ ។ អរិយសាវកនោះមិនចូលទៅជិត មិនប្រកាន់ខ្ជាប់ មិនតាំងស៊ប់នូវរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួនរបស់អញ ។ ឧបាទានក្ខន្ធទាំង៥នេះ ដែលព្រះអរិយសាវក មិនចូលទៅជិត មិនប្រកាន់ខ្ជាប់ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ។

យ. ម្នាលអាវុសោសារីបុត្ត កាសិតទំនងនេះមានដល់លោកដ៏មានអាយុទាំងឡាយឯណា លោកដ៏មានអាយុទាំងនោះបានឈ្មោះថាជា

សព្រហ្មចារី ជាអ្នកអនុគ្រោះ ចង់ឲ្យបានប្រយោជន៍ ជាអ្នកឲ្យឱវាទ ជាអ្នកប្រៀនប្រដៅ (ឥឡូវ) ចិត្តរបស់ខ្ញុំបានរួចផុត ស្រឡះចាកអាសវៈទាំងឡាយ មិនប្រកាន់មាំ (ដោយឧបាទាន) ព្រោះបានស្តាប់ព្រះធម្មទេសនា របស់ព្រះសារីបុត្តដ៏មានអាយុយ៉ាងនេះឯង ។

ចប់សេចក្តីបុច្ឆាវិសជ្ជនា របស់ព្រះថេរទាំងពីររូបតែប៉ុណ្ណេះ បើយើងគិតពិនិត្យ តាមដំណើរធម្មសាកច្ឆាដែលពោលមកនេះ នឹងឃើញថាបង្អៀតយល់ បង្អៀតស្តាប់បន្តិច ប៉ុន្តែលម្អឲ្យមើលឃើញជំរុយដែលនៅឆ្ងាយលម្ហឹមនោះបានខ្លះហើយ ទុកជាមិនច្បាស់លាស់ ក៏លម្អឲ្យយល់បានថា យោបល់របស់ព្រះអរហន្តរមែងផ្ទុយនឹងយោបល់របស់បុថុជ្ជនជាដរាប សម្បត្តិសួគ៌និងសម្បត្តិមនុស្សលោកដែលប្រកបនឹងកាមគុណទាំង ៥ ប្រការជាដើម បុថុជ្ជនតែងយល់ថាជាគួសុខសប្បាយ សឹងប្រាថ្នាចង់បានកល់គ្នា តែព្រះអរិយៈយល់ថាជាគួទុក្ខ មិនទៀងមានសេចក្តីប្រែប្រួល មិននៅក្នុងអំណាចរបស់បុគ្គលណាមួយឡើយ បច្ច័យគាត់តែងឲ្យកើតឡើងហើយ ក៏ប្រែប្រួលរលត់រលាយបាត់ទៅវិញជាធម្មតា មិនផុតអំពីជាតិ ជរា ព្យាធិ មរណៈទៅបាន · ទើបគួរនឿយណាយគួរស្អប់ខ្ពើមគួរលះបង់ទាំងអស់ មានតែព្រះនិព្វានមួយទេ ដែលជាសុខដ៏ពិតប្រាកដទៀងទាត់មិនប្រែប្រួល គេគួរប្រៀបផ្ទឹមគ្មាន ។ (ញ. ថ.)